# ស្ថានទូតជប៉ុន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

លេខ. 20 PR-17/EoJ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧

## <u>ជប៉ុនផ្តល់ ១២៤,៨៣៩ ដុល្លារអាមេរិក</u>
## <u>សម្រាប់ពង្រឹងប្រព័ន្ធថែទាំសុខភាពបឋមមាតា និងទារក នៅខេត្តកំពង់ចាម</u>

ក្រោមគ្រោងការណ៍នៃជំនួយឥតសំណង សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន រដ្ឋាភិបាលជប៉ុន ផ្តល់ថវិកាចំនួន ១២៤,៨៣៩ដុល្លារអាមេរិក ដល់អង្គការមូលនិធិជប៉ុន (អង្គការPHJ) ដើម្បីអនុវត្ត "គម្រោងពង្រឹងប្រព័ន្ធថែទាំសុខភាពបឋមមាតា និងទារក នៅខេត្តកំពង់ចាម (ដំណាក់កាលទី៣)" ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម ហូរីណូអ៊ុជិ ហ៊ីដេហ៊ីសា ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោកស្រី FUKUSHIMA Namiko ប្រធានគម្រោងនៃអង្គការPHJប្រចាំកម្ពុជា នៅស្ថានទូតជប៉ុន។

ក្នុងគម្រោងនេះ អង្គការPHJ នឹងពង្រឹងប្រព័ន្ធថែទាំសុខភាពដល់ស្រុកប្រតិបត្តិស្ទឹងត្រង់ ខេត្តកំពង់ចាម ដោយជួយពង្រឹងការគ្រប់គ្រងនៅការិយាល័យសុខាភិបាលស្រុកប្រតិបត្តិស្ទឹងត្រង់ និងនៅតាមមណ្ឌលសុខភាពគ្របដណ្តប់ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកស្ម័គ្រចិត្តសុខភាពតាមភូមិ និងការផ្តល់ការអប់រំដល់ប្រជាពលរដ្ឋក្នុងសហគមន៍ផងដែរ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ២៨.៨លានដុល្លារអាមេរិក ដល់គម្រោងចំនួន ១០១គម្រោង ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីន។ គម្រោងនេះ គឺជាគម្រោងទី២ ដែលបានផ្តល់ជូនដោយគ្រោងការណ៍នៃជំនួយនេះនៅកម្ពុជាសម្រាប់ឆ្នាំសារពើពន្ធឆ្នាំ២០១៧របស់ជប៉ុន (មេសា២០១៧ ដល់មីនា២០១៨)។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៦-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*